ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៩៣៤ ៧ស

**សូមក្រាបបង្គំទូលថ្វាយ**
**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !*

ទូលព្រះបង្គំជាខ្ញុំ បានទទួលរួចហើយនូវព្រះរាជសាររបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៦ ដើម្បីទូលព្រះបង្គំជាខ្ញុំពិនិត្យលើករណីលិខិតលេខ ១៧៩៨/១៦ គ.ស.ជ ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៦ របស់ឯកឧត្តម សម រង្ស៊ី និង ឯកឧត្តម កឹម សុខា ជាប្រធាន និងអនុប្រធានគណបក្សសង្គ្រោះជាតិ ដែលបានស្នើសុំព្រះរាជអន្តរាគមន៍ ដើម្បីលើកលែងទោស និងទម្លាក់ចោលការចោទប្រកាន់ពីតុលាការ ។

ចំពោះករណីឯកឧត្តម សម រង្ស៊ី និងឯកឧត្តម កឹម សុខា ខាងលើនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់ទូលថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតទ្រង់ព្រះមេត្តាជ្រាបដូចខាងក្រោម ៖

១-ឯកឧត្តម សម រង្ស៊ី ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ២ ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨ លានរៀល តាមអំណាចសាលក្រមព្រហ្មទណ្ឌ ៨៩ "ច" ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ និងសាលដីកាព្រហ្មទណ្ឌលេខ ១៧ ក្រ៥.ប ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍ ។ យោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរមានសមត្ថកិច្ចមានតួនាទី និងភារកិច្ចក្នុងការអនុវត្តតាមការសម្រេចនានារបស់តុលាការ ដោយអនុវត្តទៅតាមនីតិវិធីជាធរមាន ។ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញដែលជាស្ថាប័នទទួលបន្ទុកអនុវត្តសេចក្តីសម្រេចព្រហ្មទណ្ឌបានចេញដីកាបង្គាប់ឱ្យចាប់ខ្លួន កាលពីថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០១៥ ។ ប៉ុន្តែឯកឧត្តម សម រង្ស៊ី បានរត់គេចពីការតាមស្វែងរកចាប់ខ្លួនរបស់តុលាការ ដោយមិនទទួលខុសត្រូវចំពោះអំពើខុសច្បាប់របស់ខ្លួន។ទន្ទឹមនេះ បច្ចុប្បន្ន ឯកឧត្តម សម រង្ស៊ី ក៏កំពុងជាប់ពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌមួយចំនួនទៀត ដែលស្ថិតក្នុងសមត្ថកិច្ចនៃតុលាការផងដែរ ។

២-ឯកឧត្តម កឹម សុខា ត្រូវបានចោទប្រកាន់ពីបទ "បដិសេធក្នុងការចូលខ្លួន" តាមមាត្រា ៥៣៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានសាលាដំបូងរាជធានីភ្នំពេញសម្រេចផ្តន្ទាទោស

ដាក់ពន្ធនាគារកំណត់រយៈពេល ៥ ខែ និងពិន័យជាប្រាក់ចំនួន ៨ សែនរៀល តាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ២៤៦៧ "គ" ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៦ ។ ករណីនេះ ឯកឧត្តម កឹម សុខា តាមរយៈមេធាវីរបស់ខ្លួន បានសម្រេចប្តឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍រួចហើយដែរ ដែលនេះបានបង្ហាញអំពីការប្រើសិទ្ធិក្នុងការការពារខ្លួនតាមផ្លូវច្បាប់ ដោយរួមទាំងសិទ្ធិក្នុងការប្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់ក្នុងករណីដែលខ្លួនមិនសុខចិត្តចំពោះការសម្រេចនានារបស់តុលាការជាន់ទាប ហើយដែលសិទ្ធិទាំងនេះត្រូវបានធានាការពារដោយក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសធានាដោយមាត្រា ៣៨ កថាខណ្ឌទី ៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលចែងថា "ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។"

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់ទូលថ្វាយ**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតទ្រង់ព្រះមេត្តាជ្រាបថា ករណីរបស់ឯកឧត្តម សម រង្ស៊ី និងករណីរបស់ឯកឧត្តម កឹម សុខា ក៏ដូចជាករណីបុគ្គលផ្សេងទៀតដែលបានលើកឡើងនៅក្នុងលិខិតរបស់ឯកឧត្តម សម រង្ស៊ី និងឯកឧត្តម កឹម សុខា ខាងលើ គឺរឿងអនុវត្តច្បាប់សុទ្ធសាធ និងជាកិច្ចការរបស់តុលាការ ។ យោងតាមមាត្រា ១២៨ ថ្មីនិងមាត្រា ១៣០ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អំណាចតុលាការជាអំណាចឯករាជ្យ ហើយគ្មានអង្គការណាមួយ នៃអំណាចនីតិប្បញ្ញត្តិឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ ។ អ្នកប្រព្រឹត្តខុសច្បាប់ត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់ ដែលនេះគឺជារឿងធម្មតានៅក្នុងសង្គមនីតិរដ្ឋ ហើយស្របតាមស្មារតីនៃមាត្រា ៤៩ កថាខណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា "ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។" ទន្ទឹមនឹងនេះ មាត្រា ៥២ វាក្យខណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងដែរថា "រាជរដ្ឋាភិបាលកម្ពុជាត្រូវការពារនីត្យានុកូលភាពជានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។" ក្នុងន័យនេះ ក្នុងនាមជាប្រមុខរាជរដ្ឋាភិបាលកម្ពុជា ទូលព្រះបង្គំជាខ្ញុំមានជំនឿដ៏មុតមាំថា ការពង្រឹង និងការលើកកម្ពស់នីតិរដ្ឋ តាមរយៈការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់ និងមានប្រសិទ្ធភាព គឺជាការចាំបាច់ និងជាកត្តាគន្លឹះដើម្បីជួយឱ្យប្រទេសជាតិមានរបៀបរៀបរយ ស្ថិរភាព និងសន្តិសុខ ជាពិសេសជួយឱ្យលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សរបស់កម្ពុជាមានកិច្ចដំណើរការទៅមុខប្រកបដោយចីរភាព។

សេចក្តីដូចបានក្រាបបង្គំទូលថ្វាយខាងលើ សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលជ្រាបជាសេចក្តីរាយការណ៍ដ៏ខ្ពង់ខ្ពស់បំផុត ។

សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុត និងសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំ ។

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ តុលា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**